# ផ្នែកសេវាសាធារណៈទីក្រុងតាខូម៉ា
# កញ្ចប់ថវិកា និងដំណើរការអត្រាតម្លៃសម្រាប់ឆ្នាំ 2019-2020

នៅក្នុងរដូវស្លឹកឈើជ្រុះឆ្នាំ 2018 ផ្នែកសេវាសាធារណៈទីក្រុងតាខូម៉ា នឹងធ្វើការដាក់បញ្ជូនកញ្ចប់ថវិកាឆ្នាំ 2019-2020 របស់ខ្លួនសម្រាប់ការអនុម័តនៅគណៈកម្មការសេវាសាធារណៈ និងក្រុមប្រឹក្សាក្រុងនៃទីក្រុងតាខូម៉ា។ សំណើទាំងនេះ រួមបញ្ចូលទាំងការកែសម្រួលអត្រាតម្លៃសម្រាប់ផ្នែកថាមពលទីក្រុងតាខូម៉ា និងផ្នែកទឹកទីក្រុងតាខូម៉ា។

សំណើសម្រាប់កំណត់អត្រាតម្លៃសម្រាប់សេវាបរិស្ថាន (កាកសំណល់រាវ កាកសំណល់រឹង និងផ្ទៃទឹក) នឹងត្រូវធ្វើការបង្ហាញជូនទៅក្រុមប្រឹក្សាក្រុងតាខូម៉ាបន្ទាប់ពីទទួលបានការណែនាំពីគណៈកម្មការសេវាបរិស្ថាន។

### ផ្នែកថាមពលទីក្រុងតាខូម៉ាបានប៉ាន់ប្រមាណពីការកែសម្រួលអត្រាតម្លៃ

កើនឡើងជាមធ្យមជាប្រព័ន្ធ 2%
កើនឡើងជាមធ្យមសម្រាប់លំនៅដ្ឋាន 0.9%

— កើនឡើងជាមធ្យមប្រចាំខែ $0.84 ក្នុងឆ្នាំ 2019
— កើនឡើងជាមធ្យមប្រចាំខែ $0.85 ក្នុងឆ្នាំ 2020

### ផ្នែកទឹកទីក្រុងតាខូម៉ាបានប៉ាន់ប្រមាណពីការកែសម្រួលអត្រាតម្លៃ

កើនឡើងជាមធ្យមជាប្រព័ន្ធ 2.5%
កើនឡើងជាមធ្យមសម្រាប់លំនៅដ្ឋាន 2.9%

— កើនឡើងជាមធ្យមប្រចាំខែ $1.02 ក្នុងឆ្នាំ 2019
— កើនឡើងជាមធ្យមប្រចាំខែ $1.08 ក្នុងឆ្នាំ 2020

TACOMA PUBLIC UTILITIES

### ផ្នែកផ្ទៃទឹកទីក្រុងតាខូម៉ាបានប៉ាន់ប្រមាណពីការកែសម្រួលអត្រាតម្លៃ

កើនឡើងជាមធ្យមជាប្រព័ន្ធ 3.5%
កើនឡើងជាមធ្យមសម្រាប់លំនៅដ្ឋាន 3.8%

— កើនឡើងជាមធ្យមប្រចាំខែ $0.92 ក្នុងឆ្នាំ 2019
— កើនឡើងជាមធ្យមប្រចាំខែ $0.95 ក្នុងឆ្នាំ 2020

### ផ្នែកកាកសំណល់រាវទីក្រុងតាខូម៉ាបានប៉ាន់ប្រមាណពីការកែសម្រួលអត្រាតម្លៃ

កើនឡើងជាមធ្យមជាប្រព័ន្ធ 4%
កើនឡើងជាមធ្យមសម្រាប់លំនៅដ្ឋាន 4%

— កើនឡើងជាមធ្យមប្រចាំខែ $2.05 ក្នុងឆ្នាំ 2019
— កើនឡើងជាមធ្យមប្រចាំខែ $2.24 ក្នុងឆ្នាំ 2020

### ផ្នែកកាកសំណល់រឹងទីក្រុងតាខូម៉ាបានប៉ាន់ប្រមាណពីការកែសម្រួលអត្រាតម្លៃ

កើនឡើងជាមធ្យមជាប្រព័ន្ធ 3%
កើនឡើងជាមធ្យមសម្រាប់លំនៅដ្ឋាន 3.9%

— កើនឡើងជាមធ្យមប្រចាំខែ $1.73 ក្នុងឆ្នាំ 2019
— កើនឡើងជាមធ្យមប្រចាំខែ $1.80 ក្នុងឆ្នាំ 2020

Tacoma
ENVIRONMENTAL SERVICES DEPARTMENT

*អត្រាតម្លៃទាំងអស់នេះ គឺស្ថិតក្នុងដំណាក់បឋមនៅឡើយ ហើយអាចមានការផ្លាស់ប្តូរ។*

## តើកត្តាអ្វីដែលជំរុញឲ្យមានការផ្លាស់ប្តូរទាំងនេះ ?

ការកែសម្រួលអត្រាតម្លៃ គឺជាជំរុញជាសំខាន់មកពីការកើនឡើងនៃអតិផរណានៅក្នុងប្រតិបត្តិការ និងការចំណាយមូលធន។

**ផ្នែកថាមពលទីក្រុងតាខូម៉ា៖**

— គម្រោងបច្ចេកវិទ្យា រួមមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធកុងទ័រទំនើប ( AMI )
— បទប្បញ្ញត្តិនិយ័តកម្មដើម្បីគ្រប់គ្រងគ្រី និងការវិភាគផលប៉ះពាល់ធំៗពីសកម្មភាពរញ្ជួយដី
— ធ្វើឲ្យប្រសើរឡើងនូវវិធានការសន្តិសុខលើប្រព័ន្ធអ៊ីនធឺណិត

**ផ្នែកទឹកទីក្រុងតាខូម៉ា៖**

— កែលម្អ និងផ្លាស់ប្តូរថ្មីចំពោះហេដ្ឋារចនាសម្ព័ន្ធទឹកដែលមានស្រាប់
— គម្រោងបច្ចេកវិទ្យា រួមមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធកុងទ័រទំនើប ( AMI )
— បទប្បញ្ញត្តិនិយ័តកម្ម

**សេវាបរិស្ថាន៖**

ការកែសម្រួលអត្រាតម្លៃសម្រាប់ផ្នែកផ្ទៃទឹក និងកាកសំណល់រាវ គឺទទួលរងឥទ្ធិពលពីកិច្ចសហប្រតិបត្តិការរបស់យើងជាមួយនឹងគំនិតផ្តួចផ្តើមរបស់ទីក្រុងដើម្បីធ្វើការជួសជុលផ្លូវថ្នល់របស់យើង។ យើងកំពុងផ្លាស់ប្តូរ និងដំឡើងបំពង់ទុយយោតាមវិធីត្រឹមត្រូវនៅពេលដែលយើងជួសជុលផ្លូវថ្នល់របស់យើង។ ទីក្រុងក៏កំពុងធ្វើការពង្រីកប្រព័ន្ធផ្ទៃទឹកនៅភាគខាងត្បូង និងភាគខាងកើតនៃទីក្រុងតាខូម៉ា ដោយធ្វើការដំឡើងនូវបំពង់ទុយយោ និងឧទ្យានទឹកភ្លៀងនៅផ្នែកខ្លះនៃទីក្រុង ដែលពុំធ្លាប់មានហេដ្ឋារចនាសម្ព័ន្ធនេះពីមុន។ ផ្នែកកាកសំណល់រឹង កំពុងប្រឈមនឹងការកើនឡើងនៃខ្ពង់ចំណាយជាច្រើន ដោយសារបញ្ហាការរឹតបន្តឹងការកែច្នៃប្រើប្រាស់ឡើងវិញជាអន្តរជាតិ។

## តើការគ្រប់គ្រងសេវាសាធារណៈត្រូវចំណាយប្រាក់យ៉ាងដូចម្តេច ?

— ការគ្រប់គ្រងទ្រព្យសកម្មនិងគម្រោង
— ការធ្វើផែនការកម្លាំងពលកម្ម និងការអភិវឌ្ឍ
— គម្រោងកែលម្អប្រសិទ្ធភាព
— កម្មវិធីសុវត្ថិភាពដែលមានភាពប្រសើរឡើង

## តើអតិថិជនអាចធ្វើអ្វីបានខ្លះដើម្បីគ្រប់គ្រងវិក្កយបត្ររបស់ពួកគេ ?

— **ការចេញថ្លៃវិក្កយបត្រថវិកា** — ជួយដល់ការគ្រប់គ្រងថវិកាប្រចាំខែ **MyTPU.org/BudgetBilling**
— **ការអភិរក្ស** — បញ្ចុះតម្លៃសេវារបស់លោកអ្នក និងមានផលល្អចំពោះបរិស្ថាន **MyTPU.org/Rebates**
— **ជំនួយទូទាត់ប្រាក់** — កម្មវិធីនានាអាចមានផ្តល់ជូនសម្រាប់អតិថិជនដែលមានលក្ខណៈសម្បត្តិទទួលបាន **MyTPU.org/Assistance**
— **កម្ចីដែលគ្មានការប្រាក់** — គាំទ្រដល់គម្រោងកែលម្អលំនៅដ្ឋានដែលមានថាមពលប្រើប្រាស់គ្រប់គ្រាន **MyTPU.org/ZeroInterest**
— **កម្ចីសម្រាប់ការអភិរក្សប្រព័ន្ធលូទឹកស្អុយ ( Sewer Conservation Loan )** សម្រាប់ពលរដ្ឋដែលមានតម្រូវការជួសជុលប្រព័ន្ធលូទឹកស្អុយឯកជន **CityofTacoma.org/SideSewer**

## តើសហគមន៍អាចចូលរួមបានដោយរបៀបណា ?

— ពិនិត្យមើលការធ្វើការបទបង្ហាញពីការធ្វើផែនការលើប្រព័ន្ធអនឡាញ
— ចូលរួមក្នុងកិច្ចប្រជុំសាធារណៈ
— ចុះឈ្មោះដើម្បីទទួលបានការជូនដំណឹងតាមអ៊ីម៉ែល

**ចូលទៅកាន់គេហទំព័រ MyTPU.org/Rates សម្រាប់ព័ត៌មានលម្អិត**

TACOMA PUBLIC UTILITIES

Tacoma